ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខ: ៩២៦២ /ស.ណ.ពប.ស្ត /ស ៦៣
/១១២៥

# សេចក្ដីជូនដំណឹង
## ស្ដីពី
## ទិវាអនាម័យបរិស្ថានជាតិ ២៣ វិច្ឆិកា ឆ្នាំ២០២៥ ក្រោមប្រធានបទ «ទម្លាប់ស្អាត គ្រួសារស្អាត បរិស្ថានល្អ»

ក្រសួងបរិស្ថានមានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជន ស្ថាប័នពាក់ព័ន្ធ រួមទាំងវិស័យឯកជន អ្នកសារព័ត៌មានជាតិ និងអន្តរជាតិឱ្យបានជ្រាបថា ក្រសួងបរិស្ថាន សហការជាមួយរដ្ឋបាលខេត្តតាកែវ នឹងប្រារព្ធទិវាអនាម័យបរិស្ថានជាតិ ២៣ វិច្ឆិកា ក្រោមប្រធានបទ **«ទម្លាប់ស្អាត គ្រួសារស្អាត បរិស្ថានល្អ»** ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត** រដ្ឋមន្ត្រីក្រសួងបរិស្ថាន នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៥ វេលាម៉ោង ០៧:៣០នាទីព្រឹក នៅសួនច្បារមាត់បឹងតាកែវ ក្រុងដូនកែវ ខេត្តតាកែវ។

ទិវានេះរៀបចំឡើងដើម្បីលើកកម្ពស់ការយល់ដឹង ការស្រឡាញ់បរិស្ថាន និងជំរុញចលនាប្រជាពលរដ្ឋ ព្រះសង្ឃ កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ សិស្ស និស្សិត ជាពិសេសជំរុញចលនាចូលរួមក្នុងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ និងយុទ្ធសាស្ត្រចក្រាវិស័យបរិស្ថានដែលបានដាក់ចេញបន្តបន្ទាប់ និងជាជំហានៗ ផ្ដោតទៅលើមុំយុទ្ធសាស្ត្រចំនួន៣គឺ ស្អាត បៃតង និងចីរភាព។

អាស្រ័យហេតុនេះ សូមសាធារណជន និងអ្នកសារព័ត៌មានជាតិ អន្តរជាតិ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃអង្គារ ១៣ រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០២៥

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**
**ឯកឧត្តម ខ្វៃ អាទិត្យា** ជាអ្នកនាំពាក្យក្រសួងបរិស្ថាន
លេខទូរស័ព្ទ/តេលេក្រាម៖ (៨៥៥) ១២ ៦៨៣ ៩៦៨